អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
អគារ ជីអាយអេ ថៅវើរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

អត្ថបទសារព័ត៌មាន

# អេ អាយ អេ បន្តគ្រងចំណាត់ថ្នាក់លេខ 1 លើបទដ្ឋាន MDRT រយៈពេល 10 ឆ្នាំជាប់គ្នា

អេ អាយ អេ គ្រុប មានមោទនភាពក្នុងការប្រកាសកំណត់ត្រារបស់ខ្លួនជាក្រុមហ៊ុនគ្រងចំណាត់ថ្នាក់លេខ 1 លើបទដ្ឋាន MDRT នៅទូទាំងពិភពលោកសម្រាប់រយៈពេល 10 ឆ្នាំជាប់គ្នា។

AIA China, AIA Hong Kong និង AIA Thailand គឺជាទីផ្សារកំពូលទាំងបីដែលមានទីប្រឹក្សាផែនការជីវិតជាប់ជាសមាជិក MDRT ច្រើនជាងគេនៅទូទាំងពិភពលោក។

លោក Lee Yuan Siong អគ្គនាយកប្រតិបត្តិ និងជាប្រធាន អេ អាយ អេ គ្រុប មានប្រសាសន៍ថា "ខ្ញុំពិតជារីករាយដែល អេ អាយ អេគ្រុប បានក្លាយជាក្រុមហ៊ុនតែមួយគត់ដែលសម្រេចបានចំណាត់ថ្នាក់លេខ 1 ក្នុងរយៈពេល 10 ឆ្នាំជាប់ៗគ្នា។ សមិទ្ធិផលជាប្រវត្តិសាស្ត្រនេះ គឺជាសក្ខីកម្មមួយចំពោះគុណភាពដ៏ឆ្នើមរបស់ទីប្រឹក្សាផែនការជីវិតរបស់យើងខ្ញុំ ដែលជាគ្រឿងសម្គាល់ថាយើងជាអ្នកដឹកនាំក្នុងវិស័យធានារ៉ាប់រងនេះ។ ទីប្រឹក្សាផែនការជីវិតរបស់យើងខ្ញុំ គឺជាចំណុចស្នូលក្នុងការរក្សាទំនាក់ទំនងដែលអាចជឿទុកចិត្តបានជាមួយអតិថិជន ហើយពួកគាត់បានកែប្រែជីវិត និងផ្តល់ស្នាមញញឹមដល់ប្រជាជនក្នុងសហគមន៍ដែលយើងបម្រើនៅទូទាំងអាស៊ី»។

លោក Jacky Chan នាយកប្រតិបត្តិប្រចាំតំបន់ និងជាប្រធានផ្នែកចែកចាយរបស់ អេ អាយ អេ បាននិយាយថា "ខ្ញុំមានមោទនភាពសឹងតែមិនគួរឱ្យជឿចំពោះនូវសមិទ្ធិផលដែលទីប្រឹក្សាផែនការជីវិត និងថ្នាក់ដឹកនាំរបស់យើងសម្រេចបាន ដែលវាជាស្តង់ដារមាសនៅក្នុងវិស័យនេះ។ ការបន្តសម្រេចបាននូវចំនួនសមាជិក MDRT ច្រើនជាងគេនៅទូទាំងពិភពលោកជាថ្មីម្តងទៀត គឺជាការឆ្លុះបញ្ចាំងពីវិជ្ជាជីវៈ និងការយកចិត្តទុកដាក់របស់ពួកគេក្នុងការបំពេញតម្រូវការដែលកំពុងកើនឡើងរបស់អតិថិជនរបស់យើងខ្ញុំ។ យើងនៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការវិនិយោគទៅលើទីប្រឹក្សាផែនការជីវិតដែលជាកម្លាំងចលករតាមរយៈផ្តល់ការបណ្តុះបណ្តាលពិសេសៗ ដំណោះស្រាយ និងការគាំទ្រដើម្បីបន្តភាពជោគជ័យរបស់ពួកគាត់។

Million Dollar Round Table (MDRT) ត្រូវបានទទួលស្គាល់ថាជា Premier Association of Financial Professionals®។ សមាជិក MDRT ត្រូវបានតម្រូវឱ្យសម្រេចកម្រិតអប្បបរមានៃបុព្វលាភ កម្រៃជើងសារ និងប្រាក់ចំណូល ហើយរក្សាឱ្យបានជាប់លាប់នូវចំណេះដឹងវិជ្ជាជីវៈ ក្រមសីលធម៌ដ៏តឹងរ៉ឹង និងសេវាកម្មអតិថិជនឆ្នើម។

សម្រាប់ព័ត៌មានលម្អិតលើការទទួលយកដំណោះស្រាយការការពារលោកអ្នក និងគ្រួសារពី អេ អាយ អេ ខេមបូឌា លើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ និងការធានារ៉ាប់រងសុខភាពជាក្រុម សូមទាក់ទង AIA Client Care តាមរយៈលេខ 086 999 242 ឬចូលទៅកាន់គេហទំព័រ aia.com.kh។

*អំពី អេ អាយ អេ ខេមបូឌា*

*ក្រុមហ៊ុនធានារ៉ាប់រង អេ អាយ អេ ខេមបូឌា គឺជាបុត្រសម្ព័ន្ធនៃ AIA Group មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន 18 ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង។*

*ចាប់តាំងពីបើកដំណើរការនៅកម្ពុជា រាល់សកម្មភាពរបស់ អេ អាយ អេ ខេមបូឌា ធ្វើឡើងស្របតាមគោលបំណង ក្នុងការជួយឲ្យប្រជាជនកម្ពុជាឲ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ 2017 យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពដំបូងបង្អស់នៅកម្ពុជា ផ្តល់ការការពាររហូតដល់ 26 ស្ថានភាពជំងឺធ្ងន់ធ្ងរ។ ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយនៅកម្ពុជា អេ អាយ អេ ខេមបូឌា ផ្តល់ជូននូវដំណោះស្រាយជីវិតឈានមុខគេនៅលើទីផ្សារសម្រាប់ប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន រាប់ចាប់ពីគម្រោងធានារ៉ាប់រងសំខាន់ៗដែលបង្កើតឡើងស្របតាមតម្រូវការជាក់លាក់ ដែលរួមមានគម្រោងការពារលើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ថ្លៃសម្រួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស។*

*អេ អាយ អេ ខេមបូឌា ផ្តោតសំខាន់លើការណែនាំ និងជម្រុញឲ្យប្រជាជនក្នុងសង្គមទទួលយកទម្លាប់ល្អៗ ក៏ដូចជាមធ្យោបាយដើម្បីឲ្យពួកគាត់ទទួលបាននូវសុខភាពល្អ តាមរយៈគំនិតផ្តួចផ្តើម រួមមានកិច្ចសហការ ជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងលើសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ តាមរយៈយុទ្ធនាការប្រចាំឆ្នាំ Fit for Hope របស់យើងជាដើម។*

*យើងក៏ចូលរួមជួយលើកស្ទួយកុមារដែលជួបបញ្ហាជីវភាពរាប់ពាន់នាក់ផងដែរ ដោយតាមរយៈឧបត្ថម្ភដល់លីគបាល់ទាត់ AIA-ISF ដែលជាលីគបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា។ ជាងនេះទៀតសោធ យើងក៏សហការជាមួយក្លិបTottenham Hotspur ក្នុងក្របខណ្ឌ English Premier League ដែលជាដៃគូសកល និងជាក្លិបបាល់ទាត់កំពូលនៅលើពិភពលោក ដើម្បីធានាថាកុមារទាំងនោះទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។*

*អេ អាយ អេ ខេមបូឌា គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពកម្ពុជាតែមួយគត់ដែលបានទទួលពានរង្វាន់ "ក្រុមហ៊ុនល្អបំផុតសម្រាប់ការងារនៅអាស៊ី (Best Companies to Work for in Asia)" ពី HR Asia ក្នុងរយៈពេល 4ឆ្នាំជាប់គ្នាពី 2020 ដល់ 2023។ អេ អាយ អេ ខេមបូឌា មានការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ និងបច្ចុប្បន្នបានពង្រីកសាខានៅខេត្តសៀមរាប កំពត កំពង់ចាម និងបាត់ដំបង។*


***Media Contact***
***Ren Pisal***
*Corporate Communication Manager*
*Pisal-P.ren@aia.com*